ក្រសួងយុត្តិធម៌

លេខ ២៣៨ ស្នួន រប-៩៣

# ព្រះរាជាណាចក្រកម្ពុជា

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

ភ្នំពេញ ថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៩៣

## ជម្រាបមក

-ប្រធានតុលាការ គ្រប់ ខេត្ត-ក្រុង

-រដ្ឋអាជ្ញាអមតុលាការ ខេត្ត-ក្រុង

**កម្មវត្ថុៈ** -អំពីឯករាជភាព នៃចៅក្រម

**យោងៈ** -បទបញ្ញត្តិស្តីពី ប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្ត នៅក្នុងប្រទេសកម្ពុជា អន្តរកាល ដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានអនុម័ត កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ។

-សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងដូចបានជម្រាប់ជូនខាងលើ ខ្ញុំសូមជម្រាប់មកអស់លោកជាចៅក្រម និងរដ្ឋអាជ្ញា នៅតុលាការខេត្ត-ក្រុង ទូទាំងប្រទេសជ្រាបថា ដើម្បីរក្សាភាពឯករាជនៃចៅក្រមនោះ យើងជាចៅក្រមក្តី រដ្ឋអាជ្ញាអមតុលាការក្តី មិនត្រូវចូលរួមក្នុងកិច្ចការទាំងឡាយដែលទាក់ទិនដល់ការបោះឆ្នោត ដែលធ្វើឡើងដោយគណៈបក្សនានាពេលបច្ចុប្បន្ននេះឡើយ ប៉ុន្តែបើមានជនណាមួយស្នើឲ្យបំភ្លឺពីបញ្ហាច្បាប់ដែលទាក់ទងដល់កិច្ចការបោះឆ្នោតនោះ ចៅក្រមក្តី រដ្ឋអាជ្ញាក្តី អាចជួយបំភ្លឺបាន ។

យើងសង្ឃឹមជឿជាក់ថា អស់លោកពិតជាយកចិត្តទុកដាក់គោរពតាមច្បាប់ដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានអនុម័តរួចមកហើយនោះជាពុំខាន ។

ហត្ថលេខា និងត្រា

**អ៊ុក ប៊ុនឈឿន**